# របាយការណ៍ប្រចាំខែកុម្ភៈ ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ

## I. ស្ថានភាពការងាររបស់មន្ទីរ ÷

### 1. ការិយាល័យ រដ្ឋបាល និងកិច្ចការទូទៅ ÷

❖ **ស្ថានភាពបុគ្គលិកមន្ត្រីរាជការក្នុងមន្ទីរ**

ការងារគ្រប់គ្រងនិងដឹកនាំមន្ទីរមានថ្នាក់ដឹកនាំចំនួន ៤ រូប (ប្រធានមន្ទីរ និងអនុប្រធានមន្ទីរ ០៣ រូប) និងមានការិយាល័យជំនាញចំនួន ១០ ការិយាល័យ ÷

១- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ
២- ការិយាល័យផែនការ-ស្ថិតិ
៣- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
៤- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ
៥- ការិយាល័យអភិវឌ្ឍន៍សហគមន៍
៦- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ
៧- ការិយាល័យថែទាំសុខភាពជនបទ
៨- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
៩- ការិយាល័យផ្លូវជនបទ
១០- ការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងមានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចំនួន ០៧ និងក្រុងចំនួន ០១។

#### 1.1. ចំនួនមន្ត្រីរាជការ

| | |
|---|---|
| – សរុប | ÷ ១៩នាក់ |
| – ប្រុស | ÷ ១៥នាក់ |
| – ស្រី | ÷ ០៤នាក់ |
| – ចំនួនប្រពន្ធមន្ត្រីរាជការ | ÷ ០៩ នាក់ |
| – ចំនួនកូន | ÷ ១៩ នាក់ |
| – អវត្តមាន | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចូល | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចេញ | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការក្របខ័ណ្ឌថ្មី | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការបានតំឡើងប្រាក់បំណាច់មុខងារ | ÷ គ្មាន |

- ចំនួនមន្ត្រីរាជការបានតំឡើងឋានៈ ÷ ០៥នាក់
- ចំនួនមន្ត្រីរាជការចូលនិវត្តន៍ ÷ ១នាក់
- ចំនួនបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកបណ្ដែត ÷ គ្មាន
- ចំនួនមន្ត្រីរាជការដែលទៅបំពេញបេសកកម្មនៅបរទេស ÷ គ្មាន
- ចំនួនមន្ត្រីរាជការសហការជាមួយកម្មវិធី និងជាដៃគូអង្គការនានា ÷ ៤នាក់

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | សហការជាមួយអង្គការ ឬកម្មវិធី |
|---|---|---|---|---|
| ១ | សេង សារី | ប | ប្រធានមន្ទីរ | -គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ២ | ម៉ប់ ធីរិត | ប | អនុប្រធានមន្ទីរ | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៣ | ញាណ គង់ | ប | មន្ត្រី | - គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទាន បន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៤ | ឆាយ សុវណ្ណា | ស | មន្ត្រី | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |

### 1.2. ការងារលិខិតចេញ-ចូល

- *បានធ្វើទទួលលិខិតចូលក្នុងនោះមាន:*
  - លិខិតចូលពីអង្គភាពនានាក្រោមមន្ទីរចំនួន ÷២៤លើក
  - លិខិតចូលពីក្រសួង និងបណ្ដារអង្គភាពនានាក្រោមឳវាទមន្ទីរចំនួន ÷០៩លើក
- *បានធ្វើលិខិតចេញដែលក្នុងនោះមាន:*
  - លិខិតចេញទៅបណ្ដារអង្គភាពនានក្រោមមន្ទីរចំនួន ÷០៤លើក
  - លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការចំនួន ÷០៨លើក
  - លិខិតចេញទូទៅចំនួន ÷០១លើក
  - លិខិតចេញទៅក្រសួង និងបណ្ដាអង្គភាពនានា ក្រោមឳវាទមន្ទីរចំនួន ÷០៣លើក
  - លិខិតចេញវិញ្ញាបនប័ត្រវគ្គបណ្ដុះបណ្ដាលចំនួន ÷០០លើក

### 1.3. ការងាររដ្ឋបាល និងបុគ្គលិក

- បានចូលរួមប្រជុំក្រៅខេត្តចំនួន ÷១២លើក
- បានចូលរួមប្រជុំក្នុងខេត្តចំនួន ÷១៥លើក
- បានចូលរួមប្រជុំផ្ទៃក្នុងមន្ទីរចំនួន ÷១លើក

1.4. **ការងារបៀវត្ស និងពលកម្ម**

- បើកប្រាក់បៀវត្សប្រចាំខែជូនមន្ត្រីរាជការក្នុងអង្គភាព
- ធ្វើរបាយការណ៍ប្រែប្រួលទៅមន្ទីរមុខងារសាធារណៈខេត្តព្រះវិហារ។

2. **ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ**

\+ **ប្រភពថវិការដ្ឋផ្តល់**

- **ថវិកាអនុម័តឆ្នាំ២០១៦** ចំនួន ៥២៣,៥០០,០០០៛០០
  - ប្រាក់ជំពូក ៦០ ចំនួន ៧០,០០០,០០០៛
  - ប្រាក់ជំពូក ៦១ ចំនួន ១៧១,៥០០,០០០៛
  - ប្រាក់ជំពូក ៦៤ ចំនួន ២៨១,០០០,០០០៛
  - ប្រាក់ជំពូក ៦៣ ចំនួន ១,០០០,០០០៛
- **ថវិកាចំណាយសម្រាប់ខែមករា ឆ្នាំ២០១៦** ចំនួន ២១,៨៣២,៥០០៛០០
  - ប្រាក់ជំពូក ៦០ គ្មាន
  - ប្រាក់ជំពូក ៦១ គ្មាន
  - ប្រាក់ជំពូក ៦៤ ចំនួន ២១,៨៣២,៥០០៛០០
  - ប្រាក់ជំពូក ៦៣ គ្មាន

3. **ការងារផែនការ និងស្ថិតិ** ៖

- នៅថ្ងៃទី ០៣-១២ ខែកុម្ភៈ ឆ្នាំ២០១៦ រៀបចំ និងធ្វើសៀវភៅផែនការថវិកាកម្មវិធីឆ្នាំ ២០១៦ ។

4. **ការងារអធិការកិច្ច និង សវនកម្ម**៖

- គ្មាន

5. **ការងារទំនាក់ទំនងសាធារណៈ**:

- បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ២០១៥-២០១៦ ជាមួយអង្គការដៃគូ នៅខេត្តព្រះសីហនុ។

II. **សកម្មភាពការងារតាមវិស័យ** ៖

1. **សកម្មភាពផ្លូវជនបទ**

- ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៦ ចុះធ្វើបច្ចុប្បន្នភាពរៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទនៅស្រុកជ័យសែន ។

2. **សកម្មភាពការងារចុះស្រង់ទិន្នន័យ**

ក្រុមការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ ថ្នាក់ខេត្តបានចុះស្រង់ទិន្នន័យផ្លូវជនបទ ទទួលបាន លទ្ធផលដូចខាងក្រោម ៖

- ផ្លូវប្រភេទលេខ០១ ចំនួន ០៤ខ្សែ ប្រវែង ៩៥.៥ គីឡូម៉ែត្រ

- ផ្លូវប្រភេទលេខ០២ ចំនួន ១៤ខ្សែ ប្រវែង ២៦៩.៥ គីឡូម៉ែត្រ
- ផ្លូវប្រភេទលេខ០៣ ចំនួន ៣៦ខ្សែ ប្រវែង ៣៩៣.៣ គីឡូម៉ែត្រ
- ផ្លូវប្រភេទលេខ០៤ ចំនួន ៣៤៤ខ្សែ ប្រវែង ៥៣៦.៤៧៨ គីឡូម៉ែត្រ

ទិន្នន័យផ្លូវជនបទទាំងបួនប្រភេទសរុបចំនួន ៣៩៨ ខ្សែ ស្មើ ១,២៩៤.៧៧៨គម

– នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ ក្រុមការងារថ្នាក់មន្ទីរបានចុះទៅមើលការដ្ឋានការងារបញ្ចប់សុពលភាព ផ្លូវថែទាំខួបគម្រោងឆ្នាំ ២០១៥ សម្រេចលទ្ធផលបាន ១00% ចំនួន ០១ខ្សែប្រវែង ១២.០០០ ម៉ែត្រស្ថិតនៅ ឃុំគូលែនត្បូង ,ឃុំភ្នំពេញ និង ឃុំភ្នំត្បែងពីរ ស្រុកគូលែន ខេត្តព្រះវិហារ ។

3. **ការងារធ្វើបច្ចុប្បន្នភាព**

– នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ ក្រុមការងារបានចុះធ្វើបច្ចុប្បន្នភាព ស្រង់ទិន្នន័យផ្លូវជនបទ បានចំនួន០១ខ្សែប្រវែង ៣២.៤០0ម៉ែត្រ ស្ពានបេតុងចំនួន០១ កន្លែង និងលូគ្រប់ប្រភេទចំនួន១១ កន្លែង ស្ថិតនៅ ស្រុកត្បែងមានជ័យ ស្រុករវៀង និង ស្រុកជ័យសែន ខេត្តព្រះវិហារ។

4. **ការងារផ្គត់ផ្គង់ទឹកជនបទ**

– ថ្ងៃទី ០២ ដល់០៨ ខែ កុម្ភៈ ឆ្នាំ២០១៦ បានចូលរួមសម្របសម្រួលស្តីពី ការបញ្ចាំងវីដេអូរអប់រំអនាម័យដល់សហគមន៍ចំនួន ០៧ភូមិ ក្នុង ២ឃុំ (ឃុំចំរើនមានភូមិត្បែង, ភូមិប្រធាតុ, ភូមិដា និងឃុំរំដោះមានភូមិ ស្វាយប៉ាត, ភូមិថ្នល់កោង, ភូមិគោកអំពិល និងភូមិឪឡឹក) ដែលមានអ្នកចូលរួមទស្សនាចំនួនសរុប ៨៥0 នាក់ស្រី ៥៦៧នាក់ និងក្មេងៗចំនួន ២៣២នាក់ ដែលគាំទ្រ ដោយអង្គការទស្សនពិភពលោកប្រចាំ ស្រុក សង្គមថ្មី។

– ថ្ងៃទី ០៨ ដល់ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៦ បានចូលរួមសម្របសម្រួលស្តីពីការចុះតំណត់ទីតាំងអណ្តូង ស្នប់អាហ្វ្រីដេវចំនួន ២៧អណ្តូងស្នប់ក្នុងឃុំចំនួន ៣គឺឃុំម្លូព្រៃមួយ (មានភូមិពោធិ៍ទាប បាន ០៧អណ្តូង ភូមិកុល បាន០៤អណ្តូង និងភូមិម្លូព្រៃបាន០៣អណ្តូង) ឃុំម្លូព្រៃពីរ (មានភូមិប្រើសក្អកបាន ០៤អណ្តូង និង បុស្សបាន ០២អណ្តូង) និងឃុំឆែបពីរ (ភូមិដងផ្លិតបាន ២ អណ្តូង, ភូមិប្រាបាន ៣អណ្តូង, និងភូមិគុណ ភាពបាន ២ភូមិ) ដែលគាំទ្រដោយអង្គការទស្សនៈ ពិភពលោកប្រចាំស្រុកឆែប។

– ថ្ងៃទី ១៦-១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ បានសម្របសម្រួលវគ្គស្តីពី ភាពជាសាលាគំរូផ្នែកទឹកស្អាត និងអនាម័យ ដល់នាយកសាលា លោកគ្រូអ្នកគ្រូ និងមណ្ឌលសុខភាពសរុបចំនួន ២៨នាក់ ស្រី ១៧នាក់នៅការិយាល័យ អង្គការទស្សនពិភពលោកប្រចាំស្រុកគូលែន។

5. **ការងារថែទាំសុខភាពជនបទ**

– គ្មានសកម្មភាព។

6. **ការងារបណ្ដុះបណ្ដាល និង ស្រាវជ្រាវ ÷**

– គ្មានសកម្មភាព។

7. **ការងារអភិវឌ្ឍន៍សហគមន៍÷**

– ថ្ងៃទី ២៦-២៨ ខែមករា ឆ្នាំ២០១៦ ចុះបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ឃុំរៀបរយ ស្រុករវៀង មានប០៣ ភូមិ គឺភូមិបង្កួនមានចំនួន ០៧ នាក់ ស្រី ចំនួន ០៣នាក់ ភូមិស្រែមានចំនួន ០៧នាក់ ស្រី ចំនួន ០៣នាក់ ភូមិ ស្លែងទោលចំនួន ០៧នាក់ស្រីចំនួន ០៣នាក់ មនុស្សសរុបចំនួន ២១ ស្រី ចំនួន ០៩នាក់

– ថ្ងៃទី ២៩- ៣០ ខែមករា ឆ្នាំ ២១០១៦ ចុះបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ)ឃុំរហ័ស ស្រុករវៀង មាន០៦ភូមិ គឺ ភូមិអន្លង់ស្វាយ ចំនួន ០៧ នាក់ស្រីចំនួន ០៣នាក់ ភូមិកំពត ចំនួន ០៧នាក់ ស្រី ចំនួន ០៣ នាក់ ភូមិកក់ពោត ចំនួន ០៧នាក់ ស្រី ចំនួន ០២នាក់ ភូមិ ចម្លង ចំនួន០៧នាក់ ស្រី ចំនួន ០២នាក់ ភូមិ សង្វែរង ចំនួន ០៧នាក់ ស្រីចំនួន ០៣នាក់ ភូមិ ថ្កែង ចំនួន ០៧នាក់ ស្រី ចំនួន ០២នាក់ មនុស្សសរុបចំនួន ៤២នាក់ ស្រីចំនួន ១៥នាក់ បូកសរុបរួម ០២ ឃុំ ០៩ភូមិ ចំនួនមនុស្ស ៦៣ នាក់ ស្រីចំនួន ២៤នាក់។

8. **ការងារសេដ្ឋកិច្ចជនបទ÷**

– គ្មានសកម្មភាព។

9. **ការងារជនជាតិដើមភាគតិច÷**

– គ្មានសកម្មភាព។

10. **ការងារយេនឌ័រ÷**

– គ្មានសកម្មភាព

11. **ការងារ NGOs÷**

– គ្មានសកម្មភាព

12. **គម្រោង / កម្មវិធី ÷**

12.1. **កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅតាមសាលារៀន និងសហគមន៍ (គាំទ្រថវិកាដោយ** UNICEF)

– ក្រុមការងារទឹកស្អាត និងអនាម័យជនបទ បានចុះជំរុញ និងលើកទឹកចិត្ត ដល់ប្រជាពលរដ្ឋ ដែលមិនទាន់បានសាងសង់បង្គន់ អោយគាត់បានចូលរួមសាងសង់ និងប្រើប្រាស់ នៅតាមភូមិគោលដៅទាំង ១៦ភូមិ ដោយបានជំរុញឲ្យគាត់សាងសង់ និងប្រើប្រាស់បង្គន់អនាម័យគ្រួសារ។

- សម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសទី៤ ឆ្នាំ២០១៥ លើការងារទឹកស្អាត និងអនាម័យជនបទ៕